ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា
CAMBODIA WATCHDOG COUNCIL INTERNATIONAL

ក្រុងគ្រីស្ទានសាន់ ថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៨

# សេចក្តីអំពាវនាវ

## ពលរដ្ឋ និងមន្ត្រីរាជការ ចូរកុំដាក់ពាក្យជាមន្ត្រីបោះឆ្នោត តាមការជូនដំណឹង គជប

បានឃើញសេចក្តីជូនដំណឹងរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គជប) ស្តីពីការជ្រើសរើសមន្ត្រីកិច្ចសន្យារយៈពេលខ្លីជាង ១៣ ម៉ឺននាក់ សម្រាប់ការបោះឆ្នាតិជាតិ ខែកក្កដាខាងមុខនេះ លិខិតលេខ ០៥៧ គ.ជ.ប/សជណ ចុះថ្ងៃ០៨ មិថុនា ២០១៨។

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា ពិនិត្យឃើញថា ការបោះឆ្នោតជាតិ ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨ មិនអាចជាការបោះឆ្នោត តាមគន្លងលទ្ធិប្រជាធិបតេយ្យបានទេ ប៉ុន្តែវាជាការបោះឆ្នោតទៅតាមការចង់បានរបស់លោក ហ៊ុន សែន ដែលរំលោភរដ្ឋធម្មនុញ្ញធ្ងន់ធ្ងរ និងរំលោភបំពានសេចក្តីទុកចិត្តរបស់ពលរដ្ឋម្ចាស់ឆ្នោតរួចទៅហើយ ហើយបង្កភាពអាមាស នៅលើឆាកអន្តរជាតិ តាមរយៈការដាក់ទណ្ឌកម្មមន្ត្រីគ្រាក់ៗក្នុងរបប ហ៊ុន សែន ជាបឋម។

ករណីមន្ត្រីរាជការ និងពលរដ្ឋ ដាក់ពាក្យបម្រើការងារជា«មន្ត្រីបោះឆ្នោត» គឺមានន័យស្មើនឹងជួយរុញឲ្យប្រទេសកម្ពុជា កាន់ធ្លាក់ចូលជ្រៅទៅក្នុងរបបផ្តាច់ការ ដែលត្រូវទទួលរងទណ្ឌកម្មពីសហគមន៍អន្តរជាតិទ្វេឡើង។ ដល់ពេលនោះ វិស័យនាំចេញសម្លៀកបំពាក់ និងស្បែកជើង ហើយនិងវិស័យនាំចេញនានា ត្រូវបានសហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក រាំងខ្ទប់កាន់តែមានកម្រិតខ្ពស់។ តើកម្មករនិយោជិត និងអាជីវករខ្មែរ ត្រូវទទួលរងគ្រោះ ឬជួបផលប៉ះពាល់យ៉ាងណាពីរបប ហ៊ុន សែន?

ក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា សូមអំពាវនាវដល់ពលរដ្ឋខ្មែរ ធ្វើពហិការ កុំដាក់ពាក្យបម្រើការងារជាមន្ត្រីបោះឆ្នោត តាមការអំពាវនាវរបស់ គ.ជ.ប។ ជាមួយគ្នានេះ យើងខ្ញុំអំពាវនាវជាថ្មីថា **សូមពលរដ្ឋខ្មែរ មេត្តាកុំទៅបោះឆ្នោត នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៨** ដើម្បីជៀសវាការរង់បំពេញចំនួនតួលេខ ចំនួនភាគរយ និងបង្គ្រប់កិច្ចឲ្យរបប ហ៊ុន សែន។ សូមពលរដ្ឋដែលស្រឡាញ់ជាតិ ទឹកដី និងយុត្តិធម៌ សូមជ្រើសរើសយកវិធីនេះ ជាជម្រើសដ៏ល្អចុងក្រោយរបស់បងប្អូនជនរួមជាតិ។

**ប្រធានក្រុមប្រឹក្សាឃ្លាំមើលកម្ពុជា**

**ម៉ែន ណាត**

អសយដ្ឋាន ទីក្រុងគ្រីស្ទានសាន់ ប្រទេសន័រវេស៍ /ប្រអប់សំបុត្រ #Senterveien 40, Apartment 112, 4790 Lillesand, NORWAY
Phone: (+47)90818257, E-mail: post: post@cwcicambodia.com /nathamonin@gmail.com /Web: www.cwcicambodia.com